ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ធំ
លេខ : ៣៦៤៥/១៩ សដក

# សេចក្តីជូនដំណឹង

យោងប្រកាសលេខ ៥៦៤៧ ប្រក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០១៩។

រដ្ឋបាលខេត្តកំពង់ធំសូមជូនដំណឹងដល់ សិស្ស និស្សិត ដែលមានបំណងចង់ចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃឱ្យបានជ្រាបថាក្រសួងមហាផ្ទៃសម្រេចបើកឱ្យមានការប្រឡងប្រជែងជ្រើសរើស **សិស្ស និស្សិត** ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ២០១៩ នៅសាលាខេត្តកំពង់ធំ និងសាលាស្រុកតាំងគោកដូចមានខាងក្រោម ៖

**១-សាលាខេត្តកំពង់ធំ**

| | | |
|---|---|---|
| - ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ | ៖ | ចំនួន ០១ នាក់ |
| - ក្របខ័ណ្ឌមន្ត្រីក្រមការ | ៖ | ចំនួន ០១ នាក់ |
| - ក្របខ័ណ្ឌលេខាធិការរដ្ឋបាល | ៖ | ចំនួន ០២ នាក់ |

**២-សាលាស្រុកតាំងគោក**

| | | |
|---|---|---|
| - ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ | ៖ | ចំនួន ០៤ នាក់ |
| - ក្របខ័ណ្ឌមន្ត្រីក្រមការ | ៖ | ចំនួន ០៣ នាក់ |
| - ក្របខ័ណ្ឌលេខាធិការរដ្ឋបាល | ៖ | ចំនួន ០៥ នាក់ |

## ក-លក្ខខណ្ឌនៃការជ្រើសរើស

១- មានសញ្ជាតិខ្មែរ

២- មានកាយសម្បទាគ្រប់គ្រាន់មានសុខភាពល្អ។ ករណីបេក្ខជនជាជនពិការ សាមីខ្លួនមានស្ថានភាពពិការភាពសមស្រប ដែលអាចបំពេញការងារបាន។

៣-មិនប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ។

៤- ត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំហើយមិនលើសពី ២៥ ឆ្នាំ។ ការកម្រិតអាយុត្រូវបានរំកិលពី ២៥ឆ្នាំ ដល់ ៣៥ឆ្នាំ យ៉ាងច្រើនបំផុត ចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសមមូល និង៤០ឆ្នាំចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល។ បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅត្រូវលើកលែងលក្ខខណ្ឌអាយុ។

៥- ជនពិការ បេក្ខជនជាស្ត្រី និងបេក្ខជនដែលនៅតំបន់ដាច់ស្រយាល ត្រូវបានយកចិត្តទុកដាក់នៅក្នុងការប្រឡងប្រជែងជ្រើសរើសនេះ ។



វិថី ២៣ តុលា ភូមិទី៧ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | លេខទូរស័ព្ទទំនាក់ទំនង: (+855) 62 961 392 | អ៊ីម៉ែល: info@kampongthom.gov.kh

៦-បេក្ខជនត្រូវមានសញ្ញាបត្រ៖

- **ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់៖** បេក្ខជនទាំងពីរភេទត្រូវមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រតាមមុខជំនាញសំខាន់ៗ រួមមានដូចជា នីតិសាស្ត្រ សេដ្ឋកិច្ច គ្រប់គ្រង ហិរញ្ញវត្ថុ ស្ថាបត្យកម្ម ភាសាបរទេស ព័ត៌មានវិទ្យា និងជំនាញផ្សេងៗ ឬសញ្ញាបត្រសមមូល
- **ក្របខ័ណ្ឌមន្ត្រីក្រមការ៖** បេក្ខជនទាំងពីរភេទត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បូក២(ពីរ)ឆ្នាំ នៃការសិក្សាថ្នាក់បរិញ្ញាបត្រតាមមុខជំនាញដូចរៀបរាប់ខាងលើ ឬ សញ្ញាបត្រសមមូល
- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល៖** បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ញាបត្រយ៉ាងទាបបំផុតមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល។

## ខ-វិញ្ញាសារ និងថេរវេលានៃការប្រឡង

- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ៖
  - ១- ជំនាញឯកទេស ......................................................រយៈពេល ០១ម៉ោង ៣០នាទី
    (នីតិរដ្ឋបាលសាធារណៈ គ្រប់គ្រង ឬកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា)
  - ២- ភាសាអង់គ្លេស......................................................រយៈពេល ០១ម៉ោង ៣០នាទី
    (ការបកប្រែអត្ថបទ និងវេយ្យាករណ៍)
- ក្របខ័ណ្ឌមន្ត្រីក្រមការ ៖
  - ១- ជំនាញឯកទេស ......................................................រយៈពេល ០១ម៉ោង ៣០នាទី
    (នីតិរដ្ឋបាល គ្រប់គ្រង ឬកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា)
  - ២-ភាសាអង់គ្លេស ......................................................រយៈពេល ០១ម៉ោង ៣០នាទី
    (ការបកប្រែអត្ថបទ និងវេយ្យាករណ៍)
- ក្របខ័ណ្ឌមន្ត្រីលេខាធិការរដ្ឋបាល ៖
  - ១-ចំណេះដឹងទូទៅ និងកិច្ចការរដ្ឋបាល និងគណិតវិទ្យា........រយៈពេល ០១ម៉ោង ៣០នាទី
    (កម្មវិធីសិក្សាថ្នាក់ទី១០ ដល់ ថ្នាក់ទី១២)
  - ២-តែងសេចក្តី ឬការសរសេរលិខិតរដ្ឋបាល........................រយៈពេល ០១ម៉ោង ៣០នាទី
    (តែងសេចក្តី : កម្មវិធីសិក្សាថ្នាក់ទី១០ ដល់ ថ្នាក់ទី១២)

បេក្ខជនដែលមានបំណងចូលបម្រើការងារត្រូវទៅដាក់ពាក្យសុំចុះឈ្មោះ ដើម្បីចូលរួមប្រឡងប្រជែងជ្រើសរើសនៅសាលាខេត្តកំពង់ធំ (ការិយាល័យគ្រប់គ្រងបុគ្គលិក) រៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ម៉ោង **១៧:០០ នាថ្ងៃសុក្រ ទី៣០ ខែសីហា ឆ្នាំ២០១៩** ជាកាលកំណត់ចុងក្រោយ។

## គ-មណ្ឌលប្រឡង កាលបរិច្ឆេទប្រឡង

- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ
- មណ្ឌលប្រឡង ៖ **ខេត្តសៀមរាប**

-ក្របខ័ណ្ឌលេខាធិការរដ្ឋបាល

- មណ្ឌលប្រឡង ៖ **ខេត្តកំពង់ធំ (វិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក)**
- កាលបរិច្ឆេទប្រឡង ៖ **នៅថ្ងៃអាទិត្យ ទី២២ ខែកញ្ញា ឆ្នាំ២០១៩**

ព័ត៌មានផ្សេងៗទៀត សូមអញ្ជើញទាក់ទងផ្ទាល់នៅការិយាល័យគ្រប់គ្រងបុគ្គលិកសាលាខេត្តកំពង់ធំ រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈ

១- លោក **សួគ៌ ច័ន្ទតារា** នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស
លេខទូរស័ព្ទ ៖ ០៧៧ ៧១ ៣១ ៧១ ឬ០៩៦ ៦៥ ៩៥ ៦៩

២- លោកស្រី **ភឿន ធារី** ប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក
លេខទូរស័ព្ទ ៖ ០១៧ ៩២ ១៨ ៣៥ ឬ០១៦ ៩២ ៤៧ ២០

៣- លោក **ជូ វុនធីវិចិត្រា** អនុប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក
លេខទូរស័ព្ទ ៖ ០៩២ ៦០ ៤៤ ៥៥

ថ្ងៃចន្ទ ១៤ កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កំពង់ធំ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៩

**អភិបាល**

សុខ-លូ

**<u>ចម្លងជូន</u> ៖**

-ក្រសួងមហាផ្ទៃ
 ដើម្បីជូន "ជ្រាប"
-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
 ដើម្បី "ជ្រាប"
-មន្ទីរព័ត៌មាន
-សាលាក្រុង ស្រុក នៃខេត្តកំពង់ធំ
 ដើម្បី "ផ្សព្វផ្សាយ "
-ឯកសារ កាលប្បវត្តិ